អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

Cambodia Financial Intelligence Unit

# យន្តការនៃការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យរបស់បុគ្គលរាយការណ៍

ឧទ្ទេសនាមដោយ៖ លោក ផាន់ ពិជ័យវិបុល

ប្រធាននាយកដ្ឋាននីតិកម្មនិងបណ្តុះបណ្តាល

ថ្ងៃទី៧-៨ ខែវិច្ឆិកា ឆ្នាំ២០២៤

# All You Need to Know

## Suspicious Transaction Report



# មាតិកា

I. របៀបបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ

II. ទម្រង់របាយការណ៍ប្រតិបត្តិការសង្ស័យ

III. គោលការណ៍ណែនាំទូទៅ

IV. គន្លឹះសម្រាប់អនុវត្តឱ្យបានល្អប្រសើរ

# I. របៀបបញ្ជូន STR



### តើ STR ជាអ្វី?

ប្រតិបត្តិការសង្ស័យ ជាប្រតិបត្តិការទាក់ទងនឹងមូលនិធិ ដែលត្រូវបានសង្ស័យថា បានមកពីការប្រព្រឹត្តបទល្មើស ឬ ជាមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម។



### គុណសម្បត្តិនៃការរាយការណ៍តាមប្រព័ន្ធអេឡិចត្រូនិក

- ចំណាយតិច និងមានសុវត្ថិភាព
- កាត់បន្ថយការរាយការណ៍ឯកសារជាក្រដាស
- មានការបញ្ជាក់ការទទួលបាន ដោយមានលេខយោងជាក់លាក់ដែលបានបញ្ជូនត្រលប់ទៅវិញតាមអ៊ីម៉ែល
- ២៤ម៉ោង/ថ្ងៃ និង ៧ ថ្ងៃ/សប្តាហ៍ ដោយគ្រាន់តែមានអ៊ីនធឺណែត និងអ៊ីម៉ែល
- ចំណេញពេលវេលា ។

# យន្តការនៃការរាយការណ៍



# II. ទម្រង់របាយការណ៍ប្រតិបត្តិការសង្ស័យ

បំពេញព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន នៅក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យ

ប្រតិបត្តិការសង្ស័យត្រូវរាប់បញ្ចូលព័ត៌មានការយកចិត្តទុកដាក់ស្គាល់អតិថិជន

ថ្ងៃ ខែ ឆ្នាំកំណើត គឺជាចំណុចសំខាន់សម្រាប់កំណត់អត្តសញ្ញាណបុគ្គលឱ្យបានត្រឹមត្រូវ

សូមបំពេញគ្រប់ចំណុចនៅក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យ

ព័ត៌មានដែលត្រូវបំពេញក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យ ជួយធ្វើឱ្យប្រតិបត្តិការសង្ស័យកាន់តែមានគុណភាពផង និងផ្ទួរផ្ទងអត្តសញ្ញាណជនជាកម្មវត្ថុនៃការសង្ស័យឱ្យបានត្រឹមត្រូវផង។

# II. ទម្រង់របាយការណ៍ប្រតិបត្តិការសង្ស័យ

**ត្រូវឱ្យខ្លី និងមានន័យច្បាស់លាស់៖**

- សង្ខេបការសង្ស័យឱ្យខ្លី
- បរិយាយតាមលំដាប់នៃព្រឹត្តិការណ៍
- សរសេរខ្លឹមសារឱ្យសាមញ្ញ ច្បាស់លាស់ និងមានន័យគ្រប់គ្រាន់
- ចៀសវាងការសរសេរពាក្យកាត់ ដែលអាចឱ្យអ្នកយល់ច្រឡំ និងបកស្រាយខុស

**សេចក្ដីលម្អិតនៃការសង្ស័យ៖**

- 5W+H
- ដំបូងសូមសង្ខេបចំណុចសំខាន់នៃការសង្ស័យ
- ពិនិត្យរកព័ត៌មានពាក់ព័ន្ធផ្សេងៗ ដែលអាចផ្ដល់ឱ្យបន្ថែមទៀតបាន
- មូលហេតុនៃការសង្ស័យ សូមអ្នកបំពេញព័ត៌មានផ្សេងទៀតឱ្យបានគ្រប់តាមដែលអាចធ្វើទៅបាន
- បញ្ជាក់អំពីសំអាងនៃបទល្មើស បើសិនជាអាចកំណត់បាន

# II. ទម្រង់របាយការណ៍ប្រតិបត្តិការសង្ស័យ(ត)

ឯកសារគាំទ្រដែលត្រឹមត្រូវរួមមាន៖

ឯកសារភ្ជាប់រួមមាន (អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន របាយការណ៍ហិរញ្ញវត្ថុ រូបថត CCTV ព័ត៌មាន ឬប្រភពនៃប្រព័ន្ធផ្សព្វផ្សាយ ...)

**សេចក្តីលម្អិតនៃការសង្ស័យ**

តើអ្នកណាជាអ្នកធ្វើប្រតិបត្តិការ?

តើជាប្រភេទឧបករណ៍ហិរញ្ញវត្ថុអ្វី?

តើប្រតិបត្តិការកើតឡើងនៅពេលណា?

តើប្រតិបត្តិការកើតឡើងនៅកន្លែងណា?

តើប្រតិបត្តិការកើតឡើងដោយរបៀបណា?

តើហេតុអ្វីបានជាអ្នកយល់ថាប្រតិបត្តិការនោះគួរឱ្យសង្ស័យ?

# III. គោលការណ៍ណែនាំទូទៅ

បុគ្គលរាយការណ៍មិនត្រូវបញ្ជូន STR ទៅភ្នាក់ងារអនុវត្តច្បាប់ផ្សេងទៀតទេ ឬក្រុមហិរញ្ញវត្ថុ ក្រុមហ៊ុនមេ បុគ្គលសម្ព័ន្ធ ឬ សាខា

STR មិនគួរត្រូវបានប្រើប្រាស់ជាមធ្យោបាយទំនាក់ទំនង ឧទាហរណ៍ ជាមធ្យោបាយទទួលការណែនាំទេ



# IV. គន្លឹះសម្រាប់អនុវត្តឱ្យបានល្អប្រសើរ

- កំណត់ឱ្យបានច្បាស់លាស់នូវផលនៃបទល្មើសដែលសង្ស័យ និងទ្រព្យសម្បត្តិរបស់ជនល្មើស រួមបញ្ចូលទាំងប្រាក់ចំណេញដែលបានពីផលនៃបទល្មើសផង បើអាចធ្វើទៅបាន
- កំណត់មូលហេតុនៃការសង្ស័យថាទ្រព្យសម្បត្តិ គឺជាទ្រព្យសម្បត្តិជនល្មើស
- កំណត់អត្តសញ្ញាណភាគីផ្សេងៗដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិជនល្មើស
- ពិពណ៌នាឱ្យបានពេញលេញ អំពីមូលហេតុសង្ស័យទាក់ទងនឹងការសម្អាតប្រាក់
- បញ្ជាក់ពីប្រភេទសម្អាងបទល្មើស ប្រសិនបើដឹង ឬមួយមានមូលហេតុសង្ស័យគ្រប់គ្រាន់

ត្រូវចាំថា តួនាទីមួយសំខាន់
របស់បុគ្គលរាយការណ៍ក្នុង ការងារ
AML/CFT គឺ **រាយការណ៍** ។



# សូមអរគុណ!